# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងនិងការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០០៣ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២១ ស្តីពីការបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីយន្តការ វិធាន និងនីតិវិធីនៃការទទួលស្គាល់ ការលើកទឹកចិត្ត ការសម្របសម្រួល និងការបណ្តុះបណ្តាលលើផ្នែកធុរកិច្ចថ្មីឌីជីថល ដើម្បីលើកកម្ពស់សហគ្រិនភាពនិងនវានុវត្តន៍លើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សំដៅជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីឌីជីថលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ធុរកិច្ចថ្មីឌីជីថល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **គំរូដើម**(Prototype) សំដៅដល់គំរូដំបូងនៃផលិតផលឬសេវាមានលក្ខណៈច្នៃប្រឌិតឬនវានុវត្តន៍ដែលជាលទ្ធផលនៃការស្រាវជ្រាវ ដើម្បីត្រៀមដាក់ឱ្យដំណើរការអាជីវកម្ម។

២- **ធុរកិច្ចថ្មីឌីជីថល**(Digital Startup) សំដៅដល់ដំណើរការនៃការគ្រប់គ្រងនិងអភិវឌ្ឍនូវគំរូដើមនៃផលិតផលឬសេវាឌីជីថលដោយបុគ្គល មានលក្ខណៈច្នៃប្រឌិតសម្រាប់ធុរកិច្ចថ្មីដែលមានឱកាសរីកចម្រើនឆាប់រហ័ស ឬស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់នៃអាជីវកម្ម។

៣- **ធុរកិច្ចថ្មីដែលមានឱកាសរីកចម្រើនឆាប់រហ័ស**(High-Growth Startup) សំដៅដល់អាជីវកម្មដែលអាចពង្រីកនិងបង្កើនចំណូលឆាប់រហ័សដោយប្រើបច្ចេកវិទ្យាឌីជីថល និងអាចកាត់បន្ថយការចំណាយលើប្រតិបត្តិការរបស់ខ្លួន។

៤- **ផលិតផលឌីជីថល**(Digital Products) សំដៅដល់ផលិតផលទាំងឡាយណាដែលមានទម្រង់ជាឌីជីថលឬប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់ដំណើរការ រក្សាទុក វិភាគនិង/ឬបញ្ជូនទិន្នន័យឬព័ត៌មាន។

៥- **សេវាឌីជីថល**(Digital Services) សំដៅដល់សេវាទាំងឡាយណាដែលត្រូវបានផ្តល់តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

៦- **ស្ថាបនិកធុរកិច្ចថ្មីឌីជីថល**(Digital Startup Founder) សំដៅដល់បុគ្គលដែលទទួលបានវិញ្ញាបនបត្រទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ស្របតាមការកំណត់របស់អនុក្រឹត្យនេះ។

៧- **ស្ថានភាពមិនច្បាស់លាស់នៃអាជីវកម្ម**(Business Uncertainty) សំដៅដល់អាជីវកម្មដែលមានភាពមិនច្បាស់លាស់ ហើយងាយនឹងបរាជ័យ។

៨- **ប្រតិបត្តិករជំរុញធុរកិច្ចថ្មីឌីជីថល**(Digital Startup Accelerator) សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីស្របច្បាប់នៅក្រសួងពាណិជ្ជកម្មក្នុងការផ្តល់សេវាគាំទ្រដល់ធុរកិច្ចថ្មីឌីជីថល។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរជាអក្សរកាត់ថា **ក.ប.ទ.** មានសមត្ថកិច្ចគ្រប់គ្រងសម្របសម្រួល ជំរុញធុរកិច្ចថ្មីឌីជីថល និងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ដែលត្រូវបានទទួលស្គាល់ស្របតាមការកំណត់របស់អនុក្រឹត្យនេះ។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សរសេរជាអក្សរកាត់ថា **អ.ប.គ.ព.** ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុងការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការបញ្ចប់លើការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថលរួមទាំងការតាមដានអំពីវឌ្ឍនភាពនៃការវិវត្តធុរកិច្ចថ្មីឌីជីថល ដែលត្រូវបានទទួលស្គាល់ស្របតាមការកំណត់របស់អនុក្រឹត្យនេះ។

បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សរសេរជាអក្សរកាត់ថា **ប.ប.ឌ.** ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុងការផ្តល់ការលើកទឹកចិត្ត ការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេសនានាដល់ធុរកិច្ចថ្មីឌីជីថលដែលត្រូវបានទទួលស្គាល់ស្របតាមការកំណត់របស់អនុក្រឹត្យនេះ។

ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានាអាចចូលរួមធ្វើការលើកទឹកចិត្ត ការសម្របសម្រួល និងការបណ្តុះបណ្តាលលើផ្នែកធុរកិច្ចថ្មីឌីជីថល ដើម្បីចូលរួមចំណែកជំរុញសហគ្រិនភាពនិងនវានុវត្តន៍លើវិស័យទូរគមនាគមន៍

បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សំដៅជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីឌីជីថល រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

**មាត្រា៥ .–**

**អ.ប.គ.ព.** ត្រូវបង្កើតនិងរក្សាបញ្ជីនៃការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ដោយកត់ត្រានូវព័ត៌មានជាក់លាក់មួយចំនួន មានជាអាទិ៍ អត្តសញ្ញាណនៃអ្នកស្នើសុំទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ព័ត៌មាននៃធុរកិច្ចថ្មីឌីជីថល កាលបរិច្ឆេទនៃការទទួលស្គាល់ ព័ត៌មាននៃការបំពេញធុរកិច្ចថ្មីឌីជីថល និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៦ .–**

**ក.ប.ឌ.** ត្រូវជ្រើសរើសប្រតិបត្តិករជំរុញធុរកិច្ចថ្មីឌីជីថលឱ្យធ្វើជាតំណាងនិង/ឬជួយសម្រួលដល់ធុរកិច្ចថ្មីឌីជីថលដែលបានទទួលស្គាល់ដោយ **ក.ប.ឌ.** ក្នុងការងារហិរញ្ញវត្ថុ ពន្ធដារ កម្មសិទ្ធិបញ្ញា ជាអាទិ៍ តាមការចាំបាច់ក្នុងការប្រកបអាជីវកម្មស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការជ្រើសរើសប្រតិបត្តិករជំរុញធុរកិច្ចថ្មីឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ឌ.**។

## ជំពូកទី៣
## ការផ្តល់និងការបញ្ចប់ការទទួលស្គាល់ និងការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល

**មាត្រា៧ .–**

បុគ្គលដែលមានបំណងស្នើសុំការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ត្រូវដាក់ពាក្យស្នើសុំមក **អ.ប.គ.ព.** ដោយមិនមានបង់កម្រៃសេវា។

លក្ខខណ្ឌ បែបបទ និងនីតិវិធីលម្អិតក្នុងការផ្តល់និងការបញ្ចប់ការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ឌ.**។

**មាត្រា៨ .–**

បុគ្គលដែលបានស្នើសុំទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ដូចមានចែងក្នុងអនុក្រឹត្យនេះ និងទទួលបានវិញ្ញាបនបត្រទទួលស្គាល់ធុរកិច្ចថ្មីឌីជីថល ហៅថា **ស្ថាបនិកធុរកិច្ចថ្មីឌីជីថល**។

ការទទួលស្គាល់ធុរកិច្ចថ្មីឌីជីថលដូចមានចែងក្នុងអនុក្រឹត្យនេះមានសុពលភាពរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រទទួលស្គាល់ពី **អ.ប.គ.ព.**។

**មាត្រា៩ .–**

ការលើកទឹកចិត្ត ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសនានាដល់ធុរកិច្ចថ្មីឌីជីថល ដែលត្រូវផ្តល់ដោយ **ម.ប.ឌ** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ឌ.**។

**មាត្រា១០ .–**

ការទទួលស្គាល់ឋានៈជាធុរកិច្ចថ្មីឌីជីថលត្រូវបញ្ចប់ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការស្នើសុំរបស់ស្ថាបនិកធុរកិច្ចថ្មីឌីជីថល។

ខ- ការផុតសុពលភាពនៃការទទួលស្គាល់ ដូចមានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។

គ- តាមការសម្រេចរបស់រដ្ឋមន្ត្រី **ក.ប.ឌ.** លើមូលហេតុផ្សេងទៀត ដែលកំណត់ដោយប្រកាសដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះ។

បន្ទាប់ពីបញ្ចប់ការទទួលស្គាល់ឋានៈជាធុរកិច្ចថ្មីឌីជីថលហើយ បុគ្គលមានសក្តានុពលអាជីវកម្មត្រូវបានលើកទឹកចិត្តឱ្យចុះបញ្ជីពាណិជ្ជកម្មនិងបំពេញកាតព្វកិច្ចនានាស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដើម្បីបន្តដំណើរការនិងពង្រីកអាជីវកម្មតទៅមុខទៀត។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ